**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សាររំលែកមរណទុក្ខ

**គោរពជូន**

**ឯកឧត្តម ស្បោង សារ៉ាត ប្រធានក្រុមប្រឹក្សាខេត្តព្រៃវែង ព្រមទាំងក្រុមគ្រួសារ**
**ចំពោះមរណភាពរបស់ ឯកឧត្តម ឧត្តមសេនីយ៍ឯក សារ៉ាត ច័ន្ទវីរៈ**

**ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អានដ៏ជ្រាលជ្រៅ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្ដីក្ដុកក្ដួល និងសោកស្ដាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា **ឯកឧត្តម ឧត្តមសេនីយ៍ឯក សារ៉ាត ច័ន្ទវីរៈ** ត្រូវជាកូនបង្កើត **ឯកឧត្តម ស្បោង សារ៉ាត** បានទទួលមរណភាព នៅថ្ងៃអាទិត្យ ១៣រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ០៨:០០នាទីព្រឹក ក្នុងជន្មាយុ ៤០ឆ្នាំ ដោយរោគាពាធ។

ស្ថិតក្នុងវេលាដ៏សោកសង្រេង និងក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្ដែងនូវសេចក្ដីសោកស្ដាយ ស្រណោះ អាឡោះអាល័យបំផុត ជាមួយ **ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ** ចំពោះការបាត់បង់ **ឯកឧត្តម ឧត្តមសេនីយ៍ឯក សារ៉ាត ច័ន្ទវីរៈ** ជាកូនបង្កើត ស្វាមី ជាឪពុក ប្រកបដោយព្រហ្មវិហារធម៌មិនចេះរីងស្ងួត និងសង្គហធម៌ដ៏ល្អប្រពៃរបស់ក្រុមគ្រួសារ។

យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែកទុក្ខដោយសេចក្ដីសោកសង្រេងបំផុតជាមួយ **ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ** និងសូមសម្ដែងនូវការគោរពចំពោះដួងវិញ្ញាណក្ខន្ធរបស់ **ឯកឧត្តម ឧត្តមសេនីយ៍ឯក សារ៉ាត ច័ន្ទវីរៈ** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម ប្រធានក្រុមប្រឹក្សាខេត្តព្រៃវែង ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ៕

ថ្ងៃ ចន្ទ ១៤រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ហ៊ុន សុខា**